# អ្វីដែលគួរ

គួរប្រឹងស្វែងស្ដាប់ច្បាប់ប្រដៅ　　គួរស្គាល់ពាក្យខ្មៅឆៅវិជ្ជា
គួរកុំប្រមាទព្រះធម្មា　　គួរឆាប់ម្នីម្នាសាងកុសល។
គួរស្គាល់ទ្រនំទំដោយទី　　គួរកុំយាយីឲ្យអំពល់
គួរចេះប្រមាណប្រាណឲ្យយល់　　គួរដឹងឫសគល់ក្ដីវិនាស ។
គួរលះចិត្តល្មោភលោភក្នុងលាភ　　គួរលះចិត្តបាបដោយវៃឈ្លាស
គួរចោលអស្មិនិងមានះ　　គួរយកឲ្យឈ្នះក្នុងបាបធម៌។
គួរយកតម្រាប់ស័ព្ទអ្នកប្រាជ្ញ　　គួរចេះកោតខ្លាចភាពវឹកវរ
គួរធ្វើកិច្ចការណាល្អៗ　　គួរបង់អំណរហេតុនៃទុក្ខ ។
គួររស់ឲ្យចេះរិះវិចារណ៍　　គួរសាងកម្មណានាំឲ្យសុខ
គួរយកធម៌អាថ៌ជាត្រីមុខ　　គួរចេះរៀនរុករកគុណគាប់ ។
គួរលះអបាយឆ្ងាយវេរា　　គួរលះអវិជ្ជាក្ដីអភ័ព្វ
គួរគិតសាងបុណ្យជាទំលាប់　　គួរចាប់ឲ្យជាប់ភាពឧស្សាហ៍។
គួរលះទុច្ចរិតពិតទាំងបី　　គួរស្គាល់វិថីចាកកាមា
គួរសាងសុចរិតបីប្រការ　　គួរចាំសម្មាបដិបត្តិ ។
គួរចេះផ្លូវលោកនិងផ្លូវធម៌　　គួរត្រេកត្រាច់ចរតាមផ្លូវស័ត្យ
គួររស់ខ្ពស់ផុតភាពវិបត្តិ　　គួរប្រុងប្រយ័ត្នសត្រូវក្នុង ។
គួរមើលឲ្យឆ្ងាយកុំឲ្យជិត　　គួរបើងងឹតកុំឲ្យស្លុង
គួរបើភ្ញាត់លិចកុំឲ្យផុង　　គួរចេះប្រិតប្រុងចិត្តគំនិត ។
គួររៀរពុតជ្រៃជាតិនិរគុណ　　គួរកសាងគុណត្រាប់ព្រលិត
គួរគេចលក្ខណ៍ល្ងាចាកដួងចិត្ត　　គួរស៊ូគួចគិតត្រាប់ខ្នុរទុំ ។
គួរកុំយកវៃធ្វើជាគ្នា　　គួរត្រាប់កណ្ដៀរនិងសត្វឃ្មុំ ។
គួរមើលអង្គ្រងចងចិត្តជុំ　　គួរប្រមូលផ្ដុំចិត្តសាមគ្គី ។
គួរកុំត្រេកត្រាប់មេអំបៅ　　គួរខំត្រាប់ស្មៅដុះសព្វទី
គួរកុំយកទាជាមេដី　　គួរខំសំភីគិតគ្នាន់គ្នេរ ។
គួរថៃកិត្តិយសទោះអន្តរាយ　　គួរស៊ូស្វាប់កាយឲ្យរស់កេរ្តិ៍
គួរស្ដាប់ពាក្យចាស់ពីបុព្វេ　　គួរគិតរិះរេកុំក្រលាស់ ។
គួរថៃត្រកូលទោះចូលជ្រាំ　　គួរតាំងចិត្តមាំថៃជាតិសាសន៍
គួរស្គាល់ខ្លួនឯងឲ្យបានច្បាស់　　គួររើបំរះរកចំរើន ៕

និពន្ធដោយភិក្ខុ វណ្ណគុត្តោ ស្វាត សាលឿម